មាត្រា ២ ._ ចាត់ទុកជាមោឃៈនូវលិខិតនិងបទបញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងកិច្ចសន្យាជួលរវាង លោក ជា ភក្តី ជាអ្នកក្រុមហ៊ុនរីវឺរអង្គរលីមីធីត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដែលនាំអោយកិច្ចសន្យាជួលនេះ គ្មានសុពលភាព ។

មាត្រា ៣._ ប្រគល់ការគ្រប់គ្រងអគារសណ្ឋាគារអប្សរា ដែលមានទីតាំងនៅខាងកើតអាកាសយានដ្ឋានអង្គរ លើផ្ទៃដីទំហំ ៥.៧៩៧ ម៉ែត្រក្រឡា ឲ្យអាជ្ញាធរអប្សរា និងសាលាខេត្តសៀមរាប ។

មាត្រា ៤._ រាជរដ្ឋាភិបាលមិនទទួលខុសត្រូវលើការខូចខាតក្នុងអាក ដែលមិនគោរពនឹងនីតិវិធីស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

មាត្រា ៥._ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប ក្រុមហ៊ុនរីវឺរអង្គរលីមីធីត និងគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០.

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ០២/អនក្រ.បក**

**ស្តីពីការលុបចោលដីកាលេខ ១៨១ សសរ. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៥**

**របស់សាលាខេត្តសៀមរាប**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

www.pheakdeylaw.com

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីណែនាំអនុវត្តលេខ ០៣សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការអនុវត្តន៍គោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី
- យោងតាមការអនុវត្តន៍គោលការណ៍រដ្ឋបាលទូទៅ

**សម្រេច**

មាត្រា ១.- ត្រូវបានលុបចោលដីកាលេខ ១៩១សសរ. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៥ របស់គណៈខេត្តសៀមរាប ស្តីពីការប្រគល់ដីធ្លីមួយកន្លែងជូនលោក ពាន ពាយូ ដែលមានទីតាំងស្ថិតនៅកែកខាងលិចផ្លូវទៅអង្គរវត្តទល់មុខសណ្ឋាគារគ្រោះសល្ប វិក្រិត្យការខេត្ត ដោយហេតុថាការប្រគល់ដីនេះធ្វើឡើងក្រៅវង្វង់សមត្ថកិច្ចរបស់ខេត្ត និងដោយបំពានបទបញ្ញត្តិ និងគោលបទរដ្ឋបាល ដែលនាំអោយប៉ះពាល់ដល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ.០០០៦៦៨ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ គ្មានសុពលភាព ។

មាត្រា ២.- ប្រគល់ការតំរៀបក្បាលដីទីតាំងនេះ ជូនអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប ។

មាត្រា ៣.- រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងលោក ពាន ពាយូ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ០១/អនក្រ.តត**

**ស្តីពីការតែងតាំងនាយនគរបាលជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com